**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ**

**សម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

នាឱកាសប្រកបដោយនក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ គ្រិស្តសករាជ ២០១៧នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំ និងភរិយាខ្ញុំ សូមជូននូវសព្ទសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូម **សម្តេច** ទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីដឹកនាំនិងកសាងសមិទ្ធផលថ្មីៗថែមទៀតជូនជាតិមាតុភូមិនិងប្រជាពលរដ្ឋ។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរព និងស្វាមីភក្តិយ៉ាងជ្រាលជ្រៅបំផុតចំពោះវីរភាព និងភាពប៉ិនប្រសប់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ទទួលបានជោគជ័យដ៏ត្រចះត្រចង់ជាបន្តបន្ទាប់ ក្រោមកម្មវិធីនយោបាយដ៏ត្រឹមត្រូវនិងឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត សក្តានុពល ឧត្តមភាព និងស្វាមីភក្តិចំពោះជាតិមាតុភូមិ នាំមកនូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ជូនជាតិមាតុភូមិ និងប្រជាពលរដ្ឋ។

ជាថ្មីម្តងទៀតនាឱកាសដ៏ឧត្តុង្គឧត្តមនេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំ និងភរិយាខ្ញុំ សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយថែរក្សា ការពារប្រោះព្រំជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត**ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្វ្រកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ ០២៣ ៨៨៣ ២៧៤ អ៊ីមែលៈ generalsec@mod.gov.kh